**បទអន្តរាគមន៍**

**ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍**

**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ ២០២១**

**របស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ក្រសួងអភិវឌ្ឍន៍ជនបទ**

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២០

**ដោយលោក អឿន ធារិទ្ធ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍**

## សេចក្តីផ្តើម

ការអភិវឌ្ឍជនបទ គឺជាសកម្មភាពដែលដើរតួនាទីយ៉ាងសំខាន់ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិ និងការកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍ជនបទចម្រុះ ដែលជាសកម្មភាពប្រទាក់ក្រឡា និងអន្តរវិស័យ សំដៅកែប្រែទីជនបទ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋនៅជនបទឲ្យមានភាពប្រសើរឡើង។

ក្នុងនោះដែរ ការអភិវឌ្ឍសហគមន៍ គឺជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជនបទ និងបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងសមត្ថភាពសហគមន៍មូលដ្ឋាន។ ម្យ៉ាងទៀត ការងារអភិវឌ្ឍន៍សហគមន៍ គឺជាយន្តការគន្លឹះមួយ ដែលធ្វើសកម្មភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ នៅមូលដ្ឋានសំដៅធ្វើឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយាឥរិយាបថ និងផ្នត់គំនិតរបស់សហគមន៍ជនបទ ដើម្បីឲ្យការអភិវឌ្ឍមួយមានភាពជាម្ចាស់ និងប្រកបដោយនិរន្តភាព។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ជានាយកដ្ឋានជំនាញ ដែលបានចូលរួមយ៉ាងសកម្មក្នុងការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅជនបទ តាមរយៈការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការអភិវឌ្ឍភូមិចម្រុះ ការលើកកម្ពស់សន្តិសុខ

ស្បៀងជាលក្ខណៈគ្រួសារ ការបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងការបង្កើនសមត្ថភាពសហគមន៍ ដើម្បីកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយក្នុងសហគមន៍។

ក្នុងនោះ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍មានការិយាល័យចំណុះចំនួន ០៥ រួមមាន ការិយាល័យកិច្ចការទូទៅ ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាន ការិយាល័យសន្តិសុខស្បៀង ការិយាល័យ អប់រំក្រៅប្រព័ន្ធ និងការិយាល័យមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ព្រមទាំងមជ្ឈមណ្ឌលអភិវឌ្ឍន៍ ជនបទកម្ពុជា-កូរ៉េ។ ក្នុងឆ្នាំ ២០២០ នេះ នាយកដ្ឋានបានអនុវត្តការងារ ហើយទទួលបានលទ្ធផលដូច ខាងក្រោម៖

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ជាគណៈកម្មាធិការមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជារចនាសម្ពន្ធអភិវឌ្ឍន៍នៅថ្នាក់ភូមិ មានតួនាទីជួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការដឹកនាំ និង សម្របសម្រួលការងារអភិវឌ្ឍន៍ភូមិ។ ដើម្បីឲ្យ គ.អ.ភ យល់ដឹងពីតួនាទី ភារកិច្ចរបស់ខ្លួន និងមាន សមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពអភិវឌ្ឍន៍ភូមិប្រចាំឆ្នាំ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ និង មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្តបានយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាព គ.អ.ភ ជាលទ្ធផល ក្នុងឆ្នាំ ២០២០ រួមមាន៖

#### ក. សិក្ខាសាលាចែករំលែកចំណេះដឹង

ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីទទួលបន្ទុកការងារអភិវឌ្ឍន៍សហគមន៍ នៃមន្ទីរអភិវឌ្ឍន៍ ជនបទរាជធានី ខេត្ត និងអាជ្ញាធរពាក់ព័ន្ធ ដែលកំពុងអនុវត្តសកម្មភាពអភិវឌ្ឍន៍សហគមន៍ និងចូល រួមក្នុងការពង្រឹងសមត្ថភាព គ.អ.ភ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍បានរៀបចំសិក្ខាសាលាចែករំលែក ចំណេះដឹងស្តីពី គោលគំនិតនៃការអភិវឌ្ឍសហគមន៍ កាលពីថ្ងៃទី ៣-៤ ខែវិច្ឆិកា ឆ្នាំ ២០២០ នៅខេត្ត ព្រៃវែង។ សិក្ខាសាលាមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ នៃ ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តចំនួន ២៥ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ កម្ពុជា-កូរ៉េ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងកំពង់ស្ពឺ មន្ទីរពាក់ព័ន្ធ និងអង្គការដៃគូក្នុងខេត្ត ព្រៃវែង មានវត្តមានសរុបចំនួន ៨៥ នាក់ ស្រី ២២ នាក់។

#### ខ. ការបណ្តុះបណ្តាលគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)

តាមរយៈថវិកាតាមកម្មវិធីប្រចាំឆ្នាំ ២០២០ នេះ មន្ទីរអភិវឌ្ឍន៍ជនបទ ចំនួន ១០ ខេត្ត បានធ្វើការបណ្តុះបណ្តាល គ.អ.ភ ស្តីពីតួនាទី និងភារកិច្ច គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ និងសញ្ញាណចលនាភូមិថ្មី បានចំនួន ៥៦ វគ្គ មកពី ៣៩២ ភូមិ ដែលមានសិក្ខាកាមសរុប ១ ៩៦០ នាក់ ស្រី ៤៨៥ នាក់។

**តារាងលទ្ធផលនៃការបណ្តុះបណ្តាល គ.អ.ភ ដោយថវិកាកម្មវិធី ឆ្នាំ ២០២០**

| ល.រ | រាជធានី ខេត្ត | ថវិកាជាតិ | | | |
|---|---|---|---|---|---|
| | | ចំនួនវគ្គ | ភូមិសរុប | សិក្ខាកាមចូលរួម | |
| | | | | សរុប | ស្រី |
| ១ | បន្ទាយមានជ័យ | ៤ | ២៨ | ១៤០ | ៥៧ |
| ២ | ព្រៃវែង | ៦ | ៤២ | ២១០ | ៤១ |
| ៣ | សៀមរាប | ៧ | ៤៩ | ២៤៥ | ៥២ |
| ៤ | តាកែវ | ២ | ១៤ | ៧០ | ១៦ |
| ៥ | កំពង់ចាម | ៦ | ៤២ | ២១០ | ៦០ |
| ៦ | ត្បូងឃ្មុំ | ៦ | ៤២ | ២១០ | ៤១ |
| ៧ | កំពង់ស្ពឺ | ៦ | ៤២ | ២១០ | ៣៦ |
| ៨ | កំពង់ឆ្នាំង | ៦ | ៤២ | ២១០ | ៧០ |
| ៩ | កំពង់ធំ | ៦ | ៤២ | ២១០ | ៥២ |
| ១០ | កណ្តាល | ៧ | ៤៩ | ២៤៥ | ៦០ |
| សរុប | | ៥៦ | ៣៩២ | ១៩៦០ | ៤៨៥ |

**គ. ការធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ)**

ធ្វើបច្ចុប្បន្នភាព គ.អ.ភ បានចំនួន ២ ១៧៨ ភូមិ ក្នុងនោះ ភូមិមានសកម្មភាពចំនួន ១ ៩៥២ ភូមិ ភូមិគ្មានសកម្មភាពចំនួន ១២៣ ភូមិ ភូមិមានអង្គការគាំទ្រចំនួន ៧ ភូមិ ផ្លាស់ប្តូរសមាជិកភាពថ្មី ចំនួន ២ ៣០១ នាក់ នៃភូមិបច្ចុប្បន្នភាព។

**២. ការអភិវឌ្ឍភូមិចម្រុះ**

ការគាំទ្រសកម្មភាពអភិវឌ្ឍន៍ភូមិចម្រុះ គឺជាការឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ប្រជាពលរដ្ឋជនបទ ដើម្បីបង្កលក្ខណៈឲ្យសហគមន៍មានលទ្ធភាពធ្វើការអភិវឌ្ឍបានដោយខ្លួនឯង។ សកម្មភាពអភិវឌ្ឍន៍ភូមិចម្រុះ គឺជាការអន្តរាគមក្នុងរយៈពេលខ្លី សម្រាប់ឲ្យប្រជាពលរដ្ឋយល់ដឹងពីអត្ថប្រយោជន៍នៃ ការអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ចគ្រួសារ។ ហើយសកម្មភាពនេះបានរួមចំណែក

យ៉ាងសកម្មក្នុងការធ្វើឲ្យ ប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងភូមិនីមួយៗនៅជនបទ តាមរយៈការផ្តល់ជូននូវ ពូជរុក្ខជាតិ ពូជសត្វ និងស្រះចិញ្ចឹមត្រីជាដើម។ ជាលទ្ធផលក្នុងឆ្នាំ ២០២០ នាយកដ្ឋានបានគាំទ្រសកម្មភាពអភិវឌ្ឍន៍ភូមិចម្រុះរួមមាន កូនឈើហូបផ្លែ ពូជសត្វ និងស្រះគ្រួសារ លើភូមិគោលដៅចំនួន ០៥ ភូមិ នៃខេត្តចំនួន ០៤ ខេត្តគឺ

- ភូមិកញ្ចែរ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ
    - ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ០៤ ស្រះ ដល់គ្រួសារសរុប ០៤ គ្រួសារ
    - កូនឈើហូបផ្លែចម្រុះបានចំនួន ៥០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
    - កូនដូងបានចំនួន ៣០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
    - ផ្តល់កូនឈើចម្រុះ ៣០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ។
- ភូមិទ័ពស្រូវ ឃុំបន្ទាយព្រាល និងភូមិដំបូកកកោះ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
    - ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ០៨ ស្រះ ដល់គ្រួសារសរុប ០៨ គ្រួសារ
    - កូនឈើហូបផ្លែចម្រុះបានចំនួន ៨០០ ដើម ដល់គ្រួសារសរុប ២០០ គ្រួសារ
    - កូនដូងបានចំនួន ៤០០ ដើម ដល់គ្រួសារសរុប ២០០ គ្រួសារ
    - ផ្តល់កូនឈើចម្រុះ ៦០០ ដើម ដល់គ្រួសារសរុប ២០០ គ្រួសារ។
- ភូមិក្រៅ ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង
    - ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ០៤ ស្រះ ដល់គ្រួសារសរុប ០៤ គ្រួសារ
    - កូនឈើហូបផ្លែចម្រុះបានចំនួន ៥០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
    - កូនដូងបានចំនួន ៣០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
    - ផ្តល់កូនឈើចម្រុះ ៣០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ។
- ភូមិដូនយូ ឃុំជាខ្លាង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
    - ផ្តល់ស្រះគ្រួសារ ៥ម x ៦ម x ២.៥ម បានចំនួន ០៤ ស្រះ ដល់គ្រួសារសរុប ០៤ គ្រួសារ
    - កូនឈើហូបផ្លែចម្រុះបានចំនួន ៥០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
    - កូនដូងបានចំនួន ៣០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ
    - ផ្តល់កូនឈើចម្រុះ ៣០០ ដើម ដល់គ្រួសារសរុប ១០០ គ្រួសារ។

### ៣. ការបង្កើនសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ

គម្រោងលើកកម្ពស់សន្តិសុខស្បៀងជាលក្ខណៈគ្រួសារប្រចាំឆ្នាំ ២០២០ បានអនុវត្តសកម្មភាពដូចខាងក្រោម៖

- បណ្តុះបណ្តាលដល់គ្រួសារសហគមន៍ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តិ៍ចំនួន ០៧ វគ្គ សិក្ខាកាម ចូលរួមសរុបចំនួន ២៤៥ នាក់ ស្រី ១៧៤
    - ខេត្តសៀមរាប ចំនួន ០៥ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១៧៥ នាក់ ស្រី ១២៥ នាក់
    - ខេត្តកែប ចំនួន ០២ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៧០ នាក់ ស្រី ៤៩ នាក់។
- ផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើរោងជីកំប៉ុស្តបានចំនួន ០៤ ខេត្ត គឺ
    - ភូមិព្រៃនប់១ ព្រៃនប់២ ព្រៃនប់៣ និងភូមិបែកក្រុង ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើជីកំប៉ុស្ត ចំនួន ១៤០ គ្រួសារ
    - ភូមិសិតខាងលិច សិតខាងកើត ភូមិសុភី ឃុំកន្រ្ទាំ ស្រុកប្រាសាទបាគង (បុរេ) និងភូមិព្រះគោថ្មី ភូមិកណ្តោល ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប បានផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើជីកំប៉ុស្ត ចំនួន ១៧៥ គ្រួសារ
    - ភូមិថ្នល់ទទឹង ភូមិត្រពាំង ភូមិក្រើញ ភូមិព្រៃវែង ភូមិដូនទិព្វ ឃុំប្រាំបីមុំ ស្រុកថ្ពងខេត្តកំពង់ស្ពឺ បានផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើជីកំប៉ុស្ត ចំនួន ១៤០ គ្រួសារ
    - ភូមិចំការបី ចំការចេក អន្លង់ស ឃុំពងទឹក ស្រុកដំណាក់ចង្អើរ និងភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ ក្រុងកែប បានផ្តល់ពូជបន្លែចម្រុះ និងសម្ភារធ្វើជីកំប៉ុស្ត ចំនួន ១៤០ គ្រួសារ។

## ៤. ការអប់រំក្រៅប្រព័ន្ធ

ការិយាល័យអប់រំក្រៅប្រព័ន្ធ នៅក្នុងឆ្នាំ ២០២០ មានវគ្គបណ្តុះបណ្តាលចំនួន ០៧ វគ្គ មានសិក្ខាកាមចូលរួមចំនួន ២៤៥ នាក់ ស្ត្រី ១០៥ នាក់ ដែលមាន ខេត្តចំនួន ០៣ គឺ៖

- ខេត្តពោធិ៍សាត់ ០២ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៧០ នាក់ ស្រី ៣៧ នាក់
- ខេត្តបន្ទាយមានជ័យ ចំនួន ០២ វគ្គ មានសិក្ខាកាមចូលរួមចំនួន ៧០ នាក់ ស្រី ៣៧ នាក់
- ខេត្តត្បូងឃ្មុំ ០៣ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១០៥ នាក់ ស្រី ៣១ នាក់។

## ៥. ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ

ក្នុងឆ្នាំ ២០២០ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ បានបើកវគ្គបណ្តុះបណ្តាលបានចំនួន ០៥ វគ្គ ដល់សិក្ខាកាមជាមន្ត្រីរាជការ ថ្នាក់ដឹកនាំភូមិ អាជីវករ និងកសិករ ដែលបានអញ្ជើញមកពីខេត្តគោលដៅទាំង ១០ គឺ ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តពោធិ៍សាត់ ដែលមានសិក្ខាកាមសរុបចំនួន ១៧៥ នាក់ ស្រី ៦៣ នាក់គឺ៖

ក.វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម (ចំនួន ១០ ថ្ងៃ)

- វគ្គបច្ចេកទេសចិញ្ចឹមមាន់ និងភ្ញាស់កូនមាន់ ០១ វគ្គ សិក្ខាកាម ៣៥ នាក់ ស្រី ១០ នាក់

ខ. វគ្គបណ្តុះបណ្តាលរយៈពេលមធ្យម (ចំនួន ០៩ ថ្ងៃ)

- វគ្គបច្ចេកទេសផលិតសាប៊ូលាងចាន ០១ វគ្គ សិក្ខាកាម ៣៥ នាក់ ស្រី ១២ នាក់។

គ. វគ្គបណ្តុះបណ្តាលរយៈខ្លី (ចំនួន ០៥ ថ្ងៃ)

- វគ្គអភិវឌ្ឍន៍សហគមន៍ ០២ វគ្គ សិក្ខាកាម ៧៤ នាក់ ស្រី ២៩ នាក់
- វគ្គភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍសហគមន៍ ០១ វគ្គ សិក្ខាកាម ៣៥ នាក់ ស្រី ១២ នាក់។

## ៦. ការពង្រឹងសកម្មភាពមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

តាមរយៈថវិកាតាមកម្មវិធីប្រចាំឆ្នាំ ២០២០ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ និងខេត្តតាកែវ បានទទួលថវិកា សម្រាប់អនុវត្តសកម្មភាពពង្រឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទក្នុងខេត្តគោលដៅទាំង ០២ ខាងលើដោយបានបើកវគ្គបណ្តុះបណ្តាលទាំងនៅក្នុង និងក្រៅមជ្ឈមណ្ឌល សំដៅផ្តល់ចំណេះដឹងមុខជំនាញវិជ្ជាជីវៈជូនដល់ប្រជាពលរដ្ឋតាមជនបទដោយមិនយកប្រាក់កម្រៃ ជាពិសេសផ្តល់ជូនដល់ជនពិការយុវជន យុវ នារី និងស្ត្រីមេម៉ាយ ដែលពុំមានលទ្ធភាពបន្តការសិក្សាទៅមុខទៀតបាន ដើម្បីឲ្យពួកគាត់ទទួលបានចំណេះដឹង និងមានជំនាញយកទៅប្រកបមុខរបរចិញ្ចឹមជីវិតបង្កើនប្រាក់ចំណូលបន្ថែមលើការងារធ្វើស្រែចំការរួមចំណែកកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ស្របតាមគោលនយោបាយចតុកោណរបស់រាជរដ្ឋាភិបាល ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

### ក.មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ

ក្នុងឆ្នាំ ២០២០ នេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានបើកវគ្គបណ្តុះបណ្តាលនៅក្រៅមជ្ឈមណ្ឌលបានចំនួន ១០ វគ្គ (រយៈពេល ១០ ថ្ងៃ) សិក្ខាកាមសរុបចំនួន ២០០ នាក់ ស្រី ចំនួន ៧៤ នាក់ វគ្គទាំងអស់រួមមាន ៖

- វគ្គចិញ្ចឹមជ្រូកចំនួន ០១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ០៥ នាក់
- វគ្គចិញ្ចឹមមាន់ចំនួន ០៧ វគ្គ សិក្ខាកាម ១៤០ នាក់ ស្រី ៥៣ នាក់
- វគ្គដាំដំណាំគ្រួសារចំនួន ០១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ០៧ នាក់
- វគ្គបណ្តុះផ្សិតចំបើងចំនួន ០១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ០៩ នាក់។

### ខ.មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ

ក្នុងឆ្នាំ ២០២០ នេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែងចំនួន ១៥ វគ្គ មានសិក្ខាកាមចំនួន ៤៣៤ នាក់ ស្រី ២១០នាក់ ក្នុងនោះមាន៖

- វគ្គជំនាញអ៊ុតសក់ ផាត់មុ ០១ វគ្គ សិក្ខាកាម ១២ នាក់ ស្រី ១២ នាក់
- វគ្គកុំព្យូទ័ររដ្ឋបាលទូទៅ ០២វគ្គ សិក្ខាកាម ៣២ នាក់ ស្រី ១៦ នាក់

- វគ្គការថែទាំ និងជួសជុលស្នប់ ០២ វគ្គ សិក្ខាកាម ៥០ នាក់ ស្រី ១៥ នាក់
- វគ្គការចិញ្ចឹមសត្វមាន់ ០៤ វគ្គ សិក្ខាកាម ១៣៦ នាក់ ស្រី ៦០ នាក់
- វគ្គការដាំដំណាំបន្លែ ០៤ វគ្គ សិក្ខាកាម ១៣៦ នាក់ ស្រី ៧៥ នាក់
- វគ្គការចិញ្ចឹមត្រី ០២ វគ្គ សិក្ខាកាម ៦៨ នាក់ ស្រី ៣២ នាក់។

## II. បញ្ហាប្រឈម

តាមរយៈសមិទ្ធិផលដែលទទួលបានពីការអនុវត្តការងារក្នុងខែកន្លងមក នាយកដ្ឋានបានកត់សម្គាល់ឃើញថា មានបញ្ហាប្រឈមមួយចំនួនបានផ្តល់ការលំបាកក្នុងដំណើរការអនុវត្តសកម្មភាព ក៏ដូចជាកត្តារាំងស្ទះក្នុងការអភិវឌ្ឍសហគមន៍ជនបទមានដូចខាងក្រោម ៖

- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋានភាគមួយចំនួន មានជីវភាពខ្វះខាត ជាហេតុនាំឲ្យមានការធ្វើចំណាកស្រុក ហើយទៅប្រកបមុខរបរនៅប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន
- ថវិកាសម្រាប់បណ្តុះបណ្តាលពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នៅឡើយ
- ពុំទាន់មានថវិកាគាំទ្រដល់សហគមន៍ ក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍សហគមន៍
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័ន ឬអង្គការមួយចំនួន មិនប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗ
- ពុំសូវមានសមាសភាព គ.អ.ភ ជាស្ត្រី ដែលសារាចរណែនាំ ជំរុញសមាសភាពជាស្ត្រីចូលរួមឲ្យបានច្រើន។

## III. មេរៀន និងបទពិសោធន៍

### ១. ចំណុចខ្លាំង

- មានប្រកាសអន្តរក្រសួងលេខ ២ ៣៩១ ប្រ.ក ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ និងសារាចរណែនាំលេខ ០០៩៨ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់រាជធានី ខេត្ត ស្តីពី ការបង្កើត និងការប្រព្រឹត្តទៅរបស់ គ.អ.ភ
- មានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង អង្គការដៃគូ និងអាជ្ញាធរមូលដ្ឋាន ក្នុងការពង្រឹងសមត្ថភាព និងប្រើប្រាស់ គ.អ.ភ
- ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ បានគាំទ្រជាថវិកាឯកសារមេរៀន បណ្តុះបណ្តាលសមត្ថភាព សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ សិក្ខាសាលាចែករំលែកចំណេះដឹង ដល់មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ឲ្យមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការបន្តបណ្តុះបណ្តាល គ.អ.ភ

- ប្រធានបទ នៃការបណ្តុះបណ្តាលបានឆ្លើយតបទៅនឹងតម្រូវការរបស់ គ.អ.ភ និងសហគមន៍
- អាជ្ញាធរស្រុក ឃុំ និងអង្គការដៃគូ បានទទួលស្គាល់ពីសារៈសំខាន់ និងភាពចាំបាច់របស់ គ.អ.ភ ក្នុងការដឹកនាំអនុវត្តការងារអភិវឌ្ឍន៍នៅថ្នាក់ភូមិ
- គ.អ.ភ បានចូលរួមយ៉ាងសកម្មក្នុងការធ្វើផែនការវិនិយោគឃុំ សង្កាត់ ដោយបានជួយប្រមូលបញ្ហា ក្តីកង្វល់ និងកំណត់តម្រូវការ ជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងភូមិ ដើម្បីរៀបចំដាក់បញ្ចូលក្នុងផែនការ និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ តែងសហការ និងសម្របសម្រួល ជាមួយមន្ទីរ និងអង្គការជាដៃគូពាក់ព័ន្ធ ជុំវិញការរៀបចំបង្កើត ក៏ដូចជាការបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព គ.អ.ភ
- គ.អ.ភ ដែលបានទទួលការបណ្តុះបណ្តាលរួចហើយ មានការយល់ច្បាស់ពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ខ្លួន
- គ.អ.ភ បានជួយថែទាំនូវបណ្តាសមិទ្ធផលរួមនានាក្នុងភូមិ
- គ.អ.ភ ជួយតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងផ្សេងៗ នៅក្នុងភូមិ
- មានការគាំទ្រដល់ការអភិវឌ្ឍចម្រុះ ដល់គ្រួសារក្នុងភូមិគោលដៅនូវ ពូជបន្លែចម្រុះ កូនឈើហូបផ្លែ ពូជសត្វ ស្រះគ្រួសារ និងសម្ភារធ្វើជីកំប៉ុស្ត
- ប្រជាពលរដ្ឋយល់ដឹងពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះមហន្តរាយក្នុងសហគមន៍ ដោយទទួលបានការបណ្តុះបណ្តាល
- មន្ត្រីរាជការ ថ្នាក់ដឹកនាំភូមិ អាជីវករ និងកសិករ ទទួលបានចំណេះដឹងអំពីការងារអភិវឌ្ឍន៍សហគមន៍ និងផ្លាស់ប្តូរផ្នត់គំនិត តាមរយៈការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ
- ជនពិការយុវជន យុវ នារី និងស្ត្រីមេម៉ាយ ដែលពុំមានលទ្ធភាពបន្តការសិក្សាទៅមុខទៀត បានទទួលបានចំណេះដឹង និងមានជំនាញយកទៅប្រកបមុខរបរចិញ្ចឹមជីវិត បង្កើនប្រាក់ចំណូលប្រចាំថ្ងៃ តាមរយៈការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងខេត្តកំពង់ស្ពឺ។

## ២. ចំណុចខ្វះខាត

- ការកំណត់តម្រូវការអាទិភាពភូមិ និងរៀបចំផែនការអភិវឌ្ឍន៍ភូមិរបស់ គ.អ.ភ នៅមានកម្រិត
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- គ.អ.ភ មួយចំនួន មិនទាន់មានសមត្ថភាពកៀរគរធនធានក្នុង និងក្រៅភូមិ សម្រាប់អភិវឌ្ឍន៍ភូមិ
- ការគាំទ្រការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងសម្រាប់ចុះតាមដានសកម្មភាពរបស់ គ.អ.ភ របស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត មានកំណត់

- សមាជិកមួយចំនួនមិនទាន់យល់ច្បាស់ពីតួនាទី ភារកិច្ចរបស់ គ.អ.ភ។

### ៣. សំណូមពរ

- បង្កើនថវិកាសម្រាប់បណ្តុះបណ្តាល គ.អ.ភ ដល់មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត ដើម្បីឲ្យ គ.អ.ភ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអភិវឌ្ឍភូមិបានដោយខ្លួនឯង
- មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងអង្គការដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលកំពុងតែអនុវត្តគម្រោងនៅតាមភូមិគោលដៅ ប្រើប្រាស់ គ.អ.ភ អោយអស់ពីលទ្ធភាព
- បន្តសកម្មភាពបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងជំនាញផ្សេងៗ ព្រមទាំងលើកទឹកចិត្ត គ.អ.ភ តាមគ្រប់រូបភាព
- ក្រសួងអភិវឌ្ឍន៍ជនបទ អង្គការជាតិ អន្តរជាតិ ភ្នាក់ងារអភិវឌ្ឍន៍ជនបទ គាំទ្រទាំងស្មារតី សម្ភារ និងថវិកាដើម្បីឲ្យមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត មានលទ្ធភាពពង្រឹងសមត្ថភាព និងប្រើប្រាស់ គ.អ.ភ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងដំណើរការអភិវឌ្ឍន៍ជនបទដោយមានការចូលរួម
- គាំទ្រឲ្យមានស្នាក់ការភូមិសម្រាប់ គ.អ.ភ។